**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ:** ០៥០ **គ.ជ.ប**

# គោលការណ៍

## សម្រាប់

## បោះពុម្ព និងផ្សព្វផ្សាយអត្ថបទឃោសនារបស់គណបក្សនយោបាយ ក្នុងព្រឹត្តិបត្រគោលនយោបាយគណបក្ស

- អនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។
- អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។
- អនុលោមតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។
- អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- អនុលោមតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នឹងរៀបចំបោះពុម្ពព្រឹត្តិបត្រគោលនយោបាយគណបក្ស ចំនួន ២ (ពីរ) លេខ ក្នុងពេលឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។

ដើម្បីឱ្យការបោះពុម្ពព្រឹត្តិបត្រនេះប្រព្រឹត្តទៅតាមគោលការណ៍ស្មើភាព គណបក្សនយោបាយដែលបានទទួលការយល់ព្រមជាផ្លូវការដោយ គ.ជ.ប នូវការចុះបញ្ជីបេក្ខជនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានសិទ្ធិផ្តល់អត្ថបទស្តីពីគោលនយោបាយគណបក្សរបស់គណបក្សខ្លួនមក គ.ជ.ប ដើម្បីធ្វើការបោះពុម្ព និងផ្សព្វផ្សាយជាសាធារណៈដោយឥតគិតថ្លៃ ។

គ.ជ.ប សម្រេចនូវគោលការណ៍ស្តីពីការបោះពុម្ពផ្សាយដូចខាងក្រោម ៖

**១. លក្ខខណ្ឌនៃការបោះពុម្ព ៖**

១.១ អត្ថបទគោលនយោបាយគណបក្សត្រូវមានទំហំ A4 (21cm x 27cm)

| | | | |
|---|---|---|---|
| Page Setup: | - Top | = | 2 cm |
| | - Bottom | = | 2 cm |
| | - Left | = | 2.5 cm |
| | - Right | = | 1.5 cm |

១.២ គណបក្សនយោបាយនីមួយៗ ត្រូវផ្តល់នូវអត្ថបទគោលនយោបាយរបស់ខ្លួន ចំនួន ២ (ពីរ) ទំព័រ A4 ក្នុង ១ (មួយ) លេខ ។

១.៣ គណបក្សនយោបាយត្រូវរចនាអត្ថបទឃោសនាឱ្យរួចរាល់មុននឹងផ្តល់មកឱ្យ គ.ជ.ប ។

១.៤ គណបក្សនយោបាយអាចផ្តល់នូវខ្លឹមសារឃោសនារបស់ខ្លួនជាអត្ថបទក៏បាន ឬជារូបភាព សខ្មៅ ស្តីពីសកម្មភាពរបស់គណបក្សខ្លួនក៏បាន ។

១.៥ គណបក្សនយោបាយអាចផ្តល់ខ្លឹមសារនៃការឃោសនានេះជាឯកសារក្រដាស (Hard Copy) ឬជាឯកសារក្នុងកុំព្យូទ័រ (Soft Copy) ។

១.៦ គណបក្សនយោបាយត្រូវផ្តល់អត្ថបទនៃការឃោសនាមកឱ្យ គ.ជ.ប បន្ទាប់ពី គ.ជ.ប ទទួលយល់ព្រមការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ រហូតដល់ ១៤ (ដប់បួន) ថ្ងៃ យ៉ាងតិចមុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត ។

១.៧ លេខរៀងទំព័រចុះផ្សាយក្នុងព្រឹត្តិបត្រត្រូវធ្វើការចាប់ឆ្នោតដោយតំណាងគណបក្សនយោបាយ ។

## ២. ការបែងចែក និងការផ្សព្វផ្សាយ ៖

២.១ គណបក្សនយោបាយត្រូវចាត់តំណាងរបស់ខ្លួនមកទទួលព្រឹត្តិបត្រគោលនយោបាយគណបក្សនៅ គ.ជ.ប ។

២.២ គ.ជ.ប ធ្វើការបែងចែក និងផ្សព្វផ្សាយដល់ស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងអង្គការសង្កេតការណ៍បោះឆ្នោត ស្ថានទូត អ្នកសារព័ត៌មាន និងនៅតាមតូបលក់កាសែតសាធារណៈដោយឥតគិតថ្លៃ ។

## ៣. គោលការណ៍ច្បាប់ ៖

៣.១ ខ្លឹមសារអត្ថបទឃោសនារបស់គណបក្សនយោបាយ ត្រូវគោរពគោលការណ៍ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ ។

៣.២ ក្នុងករណី គ.ជ.ប ពិនិត្យឃើញខ្លឹមសារនៃអត្ថបទឃោសនាប្រាសចាកពីគោលការណ៍ច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ឆ្នាំ២០១៨ គ.ជ.ប មានសិទ្ធិស្នើសុំឱ្យធ្វើការកែតម្រូវមុននឹងបោះពុម្ពផ្សាយ ។

៣.៣ ក្នុងករណីគណបក្សនយោបាយមិនអនុវត្តតាមការស្នើសុំឱ្យកែតម្រូវ គ.ជ.ប មិនចុះផ្សាយនូវអត្ថបទឃោសនានោះឡើយ ។

៣.៤ គ.ជ.ប មិនទទួលខុសត្រូវចំពោះគណបក្សនយោបាយដែលមិនគោរពតាមចំណុច ១.៦ ខាងលើ៕

ថ្ងៃអង្គារ ១៥រោច ខែជេស្ឋ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៨

**ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រធាន**

**ស៊ិក ប៊ុនហុក**